# យល់ដឹងពីសិទ្ធិមនុស្ស

## អ្លុ ហ្លង់ ទ្បឹង ស៊ិត ប៉ាណូស



## សិទ្ធិទូទៅរបស់ប្រជាពលរដ្ឋ

## ស៊ិត ប៉ាសុន ទិ ឌូ

ទ០១៥សស

អង្គការសហការ
INTERNATIONAL COOPERATION CAMBODIA
RIDE PROJECT

# អារម្ភកថា

*ដោយឃើញថាជាទូទៅ   បងប្អូនជនជាតិដើមភាគតិចនៅតំបន់ព្រៃសាននៃ ប្រទេសកម្ពុជា ពុំសូវចេះភាសាខ្មែរ និងពុំទាន់បានយល់ដឹងពី សិទ្ធិពលរដ្ឋ អោយបានទូលំទូលាយនៅឡើយ ។ អង្គការសហការអន្តជាតិកម្ពុជាបានផ្តួចផ្តើមរៀបរៀងជាសៀវភៅមួយ គឺ សៀវភៅ យល់ដឹងពីសិទ្ធិមនុស្ស  ក្នុងគោលបំណងអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ក្នុងសហគមន៍ជនជាតិដើមភាគតិចបានយល់ដឹងបន្ថែមទៀតស្តីពីសិទ្ធិនេះ  ដើម្បី ជួយអោយប្រជាពលរដ្ឋជនជាតិដើមភាគតិចកាន់តែស្គាល់ និងចេះ ប្រើប្រាស់សិទ្ធិរបស់ខ្លួនបានត្រឹមត្រូវ ហើយមានទំនាក់ទំនងល្អក្នុងការរស់នៅ សមជាប្រជាពលរដ្ឋនៃប្រទេសប្រជាធិបតេយ្យមួយ ។*

*ការរៀបរៀងសៀវភៅ យល់ដឹងពីសិទ្ធិមនុស្ស  នេះ គឺអង្គការសហការអន្តរជាតិកម្ពុជា បានដកស្រង់ខ្លឹមសារពីច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបានបកប្រែ ពីភាសាខ្មែរ  ទៅភាសាគ្រឹង  ព្រៅ និងទំពួន ។*

*ការរៀបរៀង និងបោះពុម្ពជាលើកដំបូងនេះគ្រាន់តែជាការសាកល្បងសិនទេ ។ ដូច្នេះ ក្រុមការងារយើងខ្ញុំ សូមមិត្តអ្នកអាន មេត្តាជួយ រិះគន់កែលំអ ឬផ្តល់ជាអនុសាសន៍ដល់យើងខ្ញុំផង  យើងខ្ញុំ រីករាយរង់ចាំស្វាគមន៍ និងទទួលមតិពីគ្រប់មជ្ឈដ្ឋាន ។*

*សូមអរគុណ ។*

# សមាសភាព អ្នករៀបរៀង និង កែសម្រួល

## អ្នកបកប្រែភាសាទំពួន

លោក **មួង ភារីម** អង្គការសហការអន្តជាតិកម្ពុជា

លោក **ទីវ ស៊ីម** អង្គការសហការអន្តជាតិកម្ពុជា

## គណៈកម្មការកែសម្រួលភាសាទំពួន

លោក **ធៀង សារឿន** អង្គការសហការអន្តជាតិកម្ពុជា

លោក **ឡាន ទិត** គណៈកម្មការភាសាទំពួន

លោក **ស្រែន ក្វារ** គណៈកម្មការភាសាទំពួន

លោក **វ៉ាង វើញ** គណៈកម្មការភាសាទំពួន

# មាតិការ / កាន ពន់តើម


| លេខ រៀង | ឈ្មោះសិទ្ធិ | ទំព័រ |
|---|---|---|
| ១ | ស៊ិត អ៊្វៃ កោប | ១ |
| ២ | ប៉ាណួស ទិឌូ ទី ស៊ិត ទី ឡាខា សាម៉ើ គួប | ២ |
| ៣ | ស៊ិត ប៉ងកាន់ ដៃ អន់ ទី កាន លោប ចោរ ឡឹង មួត អុងកាន រ៉ត័ លូ ប៉ាណួស ទី អំណាច | ៣ |
| ៤ | ស៊ិត អន់ ពូ ប៉ងកាន់ ទ្រង ចាបាប់ | ៤ |
| ៥ | ស៊ិត ទី សាណា សា ហ្លោះ កុំ | ៥ |
| ៦ | ស៊ិត ពួ ឡាកោ កាណុង កាន ព្លុ អីគ | ៦ |
| ៧ | ស៊ិត ហៀនហាំ លូ អន់តគ់ ប៉ាតោ | ៧ |
| ៨ | ស៊ិត សឿ ប្រ៉ះយ៉ាង តាម ពុត ប៊ុច  លូ   រ៉ាំងហៃ រ៉ាំងខ្យា | ៨ |
| ៩ | ស៊ិត ប៉ាញ់ូសង់ លូ ប៉ុំងកើត ខាប់ខួ | ៩ |
| ១០ | ស៊ិត រ៉ុស ណាំង កានង៉ាន ប្រ៉គ័ លូ ទី កានង៉ាន ប្រ៉គ័ | ១០ |
| ១១ | ស៊ិត ប៉ាឡាច់ ប៉ានីរ លូ តង័ សោម ប៉ានីរ | ១១ |
| ១២ | ស៊ិត ប្រ៉គ័ ចារ អ៊្វៃ  លូ ចាក ឡាំ ប៉ាគ់ ណោះ ប៉ាគ់ អា | ១២ |
| ១៣ | ស៊ិត កាណុង កាន ប៉ងកាន់ លូ យរ តេះ តេះតាម លើកាណាគ័ កើត អ៊ែ ទៅ | ១៣ |
| ១៤ | ស៊ិត ម៉ុត ប្រ៉គ័ កានង៉ាន កសាង សាំងខុំ | ១៤ |
| ១៥ | ស៊ិត ម៉ុត ណួយ៉ូបាយ | ១៥ |
| ១៦ | ចាបាប់  រ៉ត់ថាគ់ធំម៉ានុញ មៀត្រាទី ៣១-៥០ . មៀត្រា ទី ៦៥-៧៥ | ១៦-២៣ |

# ១- ស៊ិត អ៊្វែ កោប



សុនសាត សួន ប៉ែត ទី ស៊ិត អ៊្វែ កោប  សាណ៊ុក ស្វាក អ៊្វ ទី ប៉ាណ្វា ស ចំ ឡ៊ាំ ប្រ៉គ័ បាប ពុត ពៀក សាម៉ាត សាម៉ង លើ ឡ្យាកោ ប៉ុាំងឡ៊ែ្យ អុះ ។

អាន ចាបាប់ វ៉តែ ធំម៉ានុញ ៣២ ទ្យេក ហ្លា ទី ១៦

## ២-  ប៉ាណូស ទិឌូ ទី ស៊ិត ទី ឡាខា សាម៉ើ គួប សោប



សុនសាត សួន ប៉ែត ទិឌូ ទី ស៊ិត ប្រ៉គ័ ណោះ ប្រ៉គ័ អា តាម ពុត  ប៊ុច ឡាក់កា សុនសាត អន់ទៀគៗ ដេល អូ ទី កាន កាគ់កាន់ វ៉ាន់កាណា ផូង៍ កាចង៍ ប៉ាណូស អ៊ិក ប៉ាណូស ឡាយ៉ាម័ អុះ ។

អាន ចាបាប់ វ៉ត័ ធំម៉ានុញ ៣១ ឡេក ហ្លា ទី ១៦

# ៣-សុិត ប៉ងកាន់ ផៃ អន់ ទី កាន លោប ចោរ ឡឹង មួត អុងកាន រ៉ែត័ លូ ប៉ាណូស ទី អំណាច



សុនសាត សួន ប៉ៃត ទី សុិត ផង ប៉ងកាន់ ឡាកោ ប៉ាគ់ តុលាកា ផានៃវ ទី ប៉ាណូស ចំ លោប រ៉ាស រួម រ៉ាស សាន់ទួ ប្រ៉ៃគ័ អន់ រ៉ាយួស ម៉ូះ ម៉ាត់ លូ ឡាកោ អន់ឱ ។ កាំឡាំង ស្រុក តេះ ទី សុិត ប្រ៉ៃគ័ កាន តស៊ូ ប៊ុន ក្រុំ (ក្រាគ់ តាំងកង់ )លើ ប៉ាណូស ប៉ាតាង ប៉ាសុន ឃឹត អន់ឌូ គួប សោប ។

*អាន ចាបាប់ រ៉ែត័ ជំម៉ានុញ ៣៩ ឡេក ហ្លា ទី ១៨ ៣៩*

# ៤-ស៊ិត អន់ ពូ ប៉ងកាន់ ទ្រង ចាបាប់



សុនសាត សួន ប៉ែត ទី ស៊ិត ប៉ងកាន់ ឡាកោ ប៉ាំងឡៃ ម៉ូះ ម៉ាត់ កាន កានឹត កានោរ ប៉ាណ្ហាស លូ រ៉ាស អំប៉ាស  អន់ឌៃ ។

អាន ចាបាប់ រ៉ត៍ ជំម៉ានុញ ៣៨ ឡេក ហ្លា ទី ១៦

# ៥-ស៊ិត ទី សាណា សា ហ្លោះ កុំ



សុនសាត សួន ប៉ែត ទី ស៊ិត ណាំង សា ណាំង កាប់ អន់ ហ្វោះ កុំ កឿ សិម ឡា កោ លូ អាគ់ភិវ៉ាត់ ឡាកោ អន់ឌៃ តាំងឡា។ រ៉ែត័ លូ ស្រុក តេះ ប្រ៉គ័ ផិនកាន លូ រ៉ះ អន់តគ់ ប៉ាតោ កា សុនសាត សួន ប៉ែត អន់ ប្រ៉គ័ ម៉ីរ ប្រ៉គ័ ណា អន់ ទី ពៀ កែ សង៉ អន់ កុំ ។

អាន ចាបាប់ រ៉ែត័ ជំម៉ានុញ ៤៦-៤៧ ឡេក ហ្លា ទី ២០

# ៦-ស៊ិត ពួ ឡាកោ កាណុាង កាន ព្លុ អីគ



សុនសាត សួន ប៉ែត ទិឌ្ឍូ ទី ស៊ិត អន់ ពូ ពុាំងហែ ពុាំខ្យា ឡាកោ គ្រឹប ហាច់ ប៉ាគ់ ហី ម៉ូអ្យា ពួយ កាំវិធី ប៉ានិត ពុាំងហែ លូ ពួ ឡាកោ តាដោះ អូ ឃឹត លៀន កាក់ លូ អូ ទី កាន កាគ់កាន់ វ៉ាន់កាណា ។

អាន ចាបាប់ រ៉ែត៍ ជំម៉ានុញ ៧២ ឡ្យេក ហ្លា ទី ២៣

# ៧- សុិត ហៀនហាំ លូ អន់តគ់ ប៉ាតោ



សុនសាត សួន ប៉ៃត ទី សុិត  មុ៉ត ហៀន គ្រឹប ថាណាគ់ លូ គ្រឹប ចារ  កាណុង ស្រុក តេះ មឿង ប៉ាថេត  កេះណោះ អូ អន់ អ្យក់ លៀន លូ អូ ទី កាន កាគ់កាន់ វ៉ាន់កាណា កាខាក់ អ៊ែលូ មួត សាស្វា ។

អាន ចាបាប់ រ៉ត័ ធំម៉ានុញ ៦៥-៦៨ ទ្បេក ហ្លា ទី ២២

# ៨-ស៊ិត រ៉ាំងហៃ រ៉ាំងខ្យា លូ សឿ ប្រ៉ះ យ៉ាង តាម ពុត ប៊ិច



សុនសាត សួន ប៉ៃត ទី ស៊ិត រ៉ាំងហៃ រ៉ាំងខ្យា លូ សឿ លើ ការ៉ុប ប្រ៉ះ យ៉ាង ឡាក់ អន់ឌៃ ប៉ាញ័ ពុត កាខាក់ សាំរ៉ាប់ សែនសាក់ អូ ទី កាន បុាំងខំ ប៉ាន់ដាំ លូ កាគ់កាន់ វ៉ាន់កាណា ឡឹង បក់ ចំ អុះ ។

អាន ចាបាប់ វ៉ត័ ធំម៉ានុញ ៤៣ ទ្បែក ហ្លា ទី ១៩

# ៩-ស៊ិត ប៉ាញ់សង់ លូ ប៉ាំងកើត ខាប់ខួ



កាម៉ាក័ លូ អង់កាន់ សុនសាត សួន ប៉ែត ទី សុិត សាម៉ើ ទៅ កាណុាង កាន ប៉ាញ់ សង់ ប៉ាញ់សា ពួយ ពុត អន់ឌ្ហែ ប៉ិច ក្ងោ ម៉ោញ កាម៉ាញ់ ម៉ោញ ។

អាន ចាបាប់ រ៉ត័ ជំម៉ានុញ ៤៩ ឡ្យេក ប្លា ទី ២០

# ១០-ស៊ិត វើុស ណាំង កានង៉ាន ប្រ៉ូគ័ លូ ទី កានង៉ាន ប្រ៉ូគ័



សុនសាត សួន ប៉ែត អូ ផា កាម៉ាក័ អង់កាន់ ទី ស៊ិត វើុស ណាំង កានង៉ាន ប្រ៉ូគ័ លូ ទី កានង៉ាន ប្រ៉ូគ័ ដាគ់ៗ តាម អន់ឌៃ អ្នុ ពួយ សង់គុំ តងកាន ។ សង់គុំ លូ វ៉ៃត័ ត្រគ់ ប៉ាំងកើត កានង៉ាន អន់ ប៉ាសុន ប្រ៉ូគ័ ។

អាន ចាបាប់ វ៉ៃត័ ធំម៉ានុញ ៣៦ ទ្បែក ហ្លា ទី ១៧

# ១១- ស៊ិត ប៉ាឡាច់ ប៉ានឹរ លូ តង៉ សោម ប៉ានឹរ



*សុនសាត សួន ប៉ែត ទិឌូ ទី ស៊ិត កាណុាង៍ កាន កាកាប ប៉ាឡាច់ ប៉ានឹរ វ៉ះ សារ លូ អ្នុ ប៉ូរ៉ាមៀន ពួយ ពុត អន់ឌៃ ។*

អាន ចាបាប់ វ៉ត័ ធំម៉ានុញ ៤១ ឡេក ហ្លា ទី ១៩

# ១២-ស៊ិត ប្រ៉គ័ ចារ អ៊្វែ លូ ចាក ឡាំ ប៉ាគ់ ណោះ ប៉ាគ់ អា




*សុនសាត សួន ប៉ែត ទី ស៊ិត ប្រ៉គ័ ចារ អ្វែ ( ប៉ុំងកើត ស្រុក ណាវ្គ )ប្រ៉គ័ ហី គ្រាន ហះ ចំ កា ដាគ់ លូ ចាក ឡាំ ប៉ាគ់ ណោះ ប៉ាគ់ អា អូ ផា ចារ ចាំង ហាយ្គ ក្យាម័ តាម ពុត អន់ឌៃ ប៉ិច លើ ទី ស៊ិត សឹត ប៉ាគ់ ស្រុក តេះ អន់ឌៃ តាំងឡា ណាវ្គ ។*

*អាន ចាប៉ាប់ រត័ ជម្ពុញ ៤០ ឡ្យេក ហ្លា ទី ១៨*

# ១៣-សុិត យរ លូ ប៉ងកាន់ តេះ តាម ព្រី ទៀក លូ កាណា គ័ កើត អ៊ែ ទៅ



សុនសាត សួន ប៉ែត ទី សុិត ពុំងហែ ពុំងខ្យា  លូ យរ អ្យក់ ឡាប់ផុន ឡឹង  តេះ តាម លូ កាណាគ័ កើត អ៊ែ ទៅ កឿ កសាង ស្រុក តេះ បក់ អន់ឱ អ្វែ យរ តាម កាន ឡាប័ យើយ ។

អាន ចាបាប់ វ៉ត័ ជំម៉ានុញ ៤៤ ឡៀក ហ្លា ទី ១៨

# ១៤- សុិត ម៉ុត ប្រ៉េគ័ កានង៉ាន កសាង សង់ខុំ



សុនសាត សួន ប៉ែត ទី សុិត ម៉ុត តង័ ទិ ឡឹង ពុត ពៀក កាណុង កាន ប៉ុំងកើត ផិនកាន កេះណោះ រើស អ្យក់ អ៊ែចំ ឡាក់ ត្រគ់ ប្រ៉េគ័ អន់ទ្រូល ឡឹង ពូ លូ ឡាបៀប ប្រ៉េគ័ ង៉ោរ អន់ ត្រគ់ នៃវ កឿ អាគ់គិវ៉ាត់ កាំវិធី អាគ់គិវ៉ាត់ សិតតាកិច ង៉ោរ សង់កុំ លូ សាំងខុំ ម៉ោហ អន់ ត្រគ់ ពួយ ស្រុក តេះ អន់ខ្មែ ។

អាន ចាបាប់ រ៉ែត័ ធំម៉ានុញ ៤៩ ទ្បេក ហ្បា ទី ២១

# ១៥-សិុត ម៉ុត ណ្វាយ៉ូបាយ



សុនសាត សួន ប៉ែត ទី សិុត ម៉ុត អ្វៃ កាណុង កាណាគ់ ប៉ាគ់ ចំ កា ដាគ់ ដក់កា ពិន ប៉ាញ័ ពុត លូ ទី សិុត បោះ សាណោត កា កាណាគ់ ប៉ាគ់ ចំ ឡាក់ ពិន ប៊ិុច បោះ។

អាន ចាបាប់ វ៉ាត័ ជំម៉ានុញ ៣៤-៣៥ ឡេក ហ្លា ទី ១៦

# រដ្ឋធម្មនុញ្ញ

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

## ទំពូកទី ៣
## អំពី សិទ្ធិ និងករណីយកិច្ច របស់ប្រជាពលរដ្ឋខ្មែរ

មាត្រា ៣១--

ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមាន ចែងក្នុង ធម្មនុញ្ញ នៃអង្គការសហប្រជាជាតិសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។

ប្រជាពលរដ្ឋខ្មែរ មានភាពស្មើគ្នានៅចំពោះមុខច្បាប់ មានសិទ្ធិ សេរីភាព និង ករណីយកិច្ចដូចគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិឋានៈសង្គមធនធាន ឬស្ថានភាពឯទៀតឡើយ ។ ការប្រសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិ សេរីភាពនេះ ត្រូវ ប្រព្រឹត្តតាមលក្ខខណ្ឌ កំណត់ក្នុងច្បាប់ ។

មាត្រា ៣២--

ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន ។

ទោសប្រហារជីវិតមិនត្រូវឱ្យមានឡើយ ។

មាត្រា ៣៣--

ប្រពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។

ប្រជាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ។

ការទទួលសញ្ជាតិខ្មែរត្រូវកំណត់ក្នុងច្បាប់ ។

មាត្រា ៣៤-- ថ្មី

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ឆ្នាំ មានសិទ្ធិ បោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ឆ្នាំ អាចមានឈរឈ្មោះ ឱ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ៤០ឆ្នាំ អាចមានឈរឈ្មោះ ឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា ។

បទប្បញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត ត្រូវចែងក្នុងច្បាប់បោះឆ្នោត ។

មាត្រា ៣៥--

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ ។

សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋត្រូវបានទទួលការពិនិត្យនិងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ ។

មាត្រា ៣៦--

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរសមស្របតាម សមត្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នា ចំពោះការងារដូចគ្នា ។

ការងារមេផ្ទះមានតម្លៃស្មើគ្នា នឹងកំរៃដែលបានមកពីការងារធ្វើការនៅក្រៅផ្ទះ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និង អត្ថប្រយោជន៍ខាងសង្គមកិច្ច ដែលមានចែងក្នុច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃសហជីពនឹងមានកំណត់ក្នុងច្បាប់ ។

មាត្រា ៣៧--

សិទ្ធិធ្វើកូដកម្ម និងសិទ្ធិបាតុកម្មដោយសន្តិវិធីយកមកអនុវត្តនៅក្នុង ក្របខ័ណ្ឌនៃច្បាប់ ។

**មាត្រា ៣៨--**

ច្បាប់រាំងមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ។

ច្បាប់ការពារជីវិត កិត្តិយស និង សេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ។

ការចោទប្រកាន់ ការចាប់ខ្លួនការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារត្រូវហាមឃាត់មិនឱ្យធ្វើឡើយ ។អ្នកដែលដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិតត្រូវទទួលទោសតាមច្បាប់ ។

ការទទួលសារភាព ដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ ។

វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់ កាត់ទោសជាស្ថាពរ ។

ជនគ្រប់រូប មានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។

**មាត្រា ៣៩--**

ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ប្តឹងទារសំណងជួសជុលការ ខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និង របស់បុគ្គលិកនៃអង្គការទាំងនោះ ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុល ការខូចខាតជាសមត្ថកិច្ចរបស់តុលាការ ។

**មាត្រា ៤០--**

សេរីភាពក្នុងការធ្វើដំណើរឆ្ងាយជិត និងតាំងទីលំនៅក្នុងស្ថានភាពស្របច្បាប់របស់ប្រជាពលរដ្ឋត្រូវបានគោរព ។

ប្រជាពលរដ្ឋខ្មែរ អាចចេញទៅតាំងលំនៅ នៅប្រទេសក្រៅ ឬវិលត្រឡប់ មកវិញបាន ។

ការរក្សាសិទ្ធិមិនឱ្យរំលោភលើលំនៅឋាន និងអាថ៌កំបាំង នៃការឆ្លើយឆ្លងតាម -

-លិខិត  តាមសារទូលេខ ទូរពុម្ព ទូរគមន៍ និងតាមទូរស័ព្ទត្រូវបានធានា ។

ការឆែកឆេរលំនៅឋាន សម្ភារៈវត្ថុ និងលើរូបបុគ្គលត្រូវធ្វើឱ្យស្របនឹងបញ្ញត្តិច្បាប់ ។

## មាត្រា ៤១--

ប្រជាពលរដ្ឋខ្មែរ  មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន  សេរីភាព ខាងសារព័ត៌មាន  សេរីខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយមិនអាចឆ្លៀតបើសិទ្ធិនេះ  ដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទំលាប់ ល្អរបស់សង្គមដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិ បានឡើយ។

របបសារព័ត៌មាន  ត្រូវរៀបចំឡើងដោយច្បាប់ ។

## មាត្រា ៣២--

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសមាគម និងគណៈបក្សនយោបាយ  ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងឡាយ   អាចចូលរួមក្នុងអង្គការមហាជនជួយគ្នាទៅវិញទៅមក   ការពារសមិទ្ធផលជាតិ និងសណ្តាប់ធ្នាប់សង្គម  ។

## មាត្រា ៤៣--

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិពេញទីខាងជំនឿ ។

សេរីភាពខាងជនឿ និងការប្រតិបត្តិតាមខាងផ្លូវសាសនាត្រូវបានរដ្ឋធានាក្នុងលក្ខខណ្ឌ ដែលមិនប៉ះពាល់  ដល់ជនឿ ឬសាសនាដទៃដល់សណ្តាបធ្នាប់ និងសន្តិសុខសាធារណៈ ។

ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។

## មាត្រា ៤៤--

ជនណាក៏ដោយ ទោះជាបុគ្គលក្តី  ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គល  ដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ។

កម្មសិទ្ធិឯកជនស្របច្បាប់ ឋិតនៅក្រោមការគាំពារនៃច្បាប់ ។

ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍ សាធារណៈ តម្រូវឱ្យធ្វើក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្ដល់សំណងជា មុន ដោយសមរម្យ និងយុត្តិធម៌ ។

មាត្រា ៤៥--

ការរើសអើងគ្រប់ភេទ ប្រឆាំងនឹងស្ត្រីភេទ ត្រូវបំបាត់ចោល ។

ការធ្វើអាជីវកម្មលើការងាររបស់ស្ត្រីត្រូវហាមឃាត់ ។

បុរសនិងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ជាពិសេសក្នុង អាពាហ៍ពិពាហ៍ និងគ្រួសារ ។

អាពាហ៍ពិពាហ៍ត្រូវធ្វើតាមលក្ខខណ្ឌ ដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ ស្ម័គ្រចិត្ត ប្ដីមួយ ប្រពន្ធមួយ ។

មាត្រា ៤៦--

អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់នារីត្រូវហាមឃាត់ ។

ត្រូវហាមឃាត់មិនឱ្យមានការបញ្ឈប់នារីពីការងារដោយមូលហេតុមានគភ៌។ នារីមានសិទ្ធិឈប់សំរាកនៅពេលសម្រាលកូន ដោយទទួលប្រាក់បៀវត្ស និងដោយមាន ការធានារក្សាសិទ្ធិអតីតភាពក្នុងការងារ និងអត្ថប្រយោជន៍សង្គមផ្សេងៗទៀត ។

រដ្ឋនិងសង្គមត្រូវយកចិត្តទុកដាក់បង្កលក្ខណៈឱ្យនារី ជាពិសេសនារីជនបទ ដែលគ្មានទីពឹងបានទទួលការឧបត្ថម្ភ ដើម្បីមានមុខរបរមានលទ្ធិភាពព្យាបាលជម្ងឺ ឱ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ ។

មាត្រា ៤៧--

មាតាបិតា មានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំឱ្យទៅជាពលរដ្ឋល្អ ។

កូនមានករណីកិច្ចចិញ្ចឹម និងបីបាច់ថែរក្សាមាតាបិតា ដែលចាស់ជរាតាម ទំនៀមទំម្លាប់ខ្មែរ ។

**មាត្រា ៤៨--**

រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញា ស្តីពីកុមារ ជាពិេសសសិទ្ធិមានជីវិតរស់នៅសិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបាន ទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំង នឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ ។

រដ្ឋគាំពារប្រឆាំងនិងការងារទាំងឡាយ ដែលអាចធ្វើឱ្យ ខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាព របស់កុមារ ។

**មាត្រា ៤៩--**

ប្រជាពលរដ្ឋខ្មែរគ្រប់រូប ត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់ ។

ប្រជាពលរដ្ឋខ្មែរគ្រប់រូប មានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ ។

កាតព្វកិច្ចការពារមាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់ ។

**មាត្រា ៥០--**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវគោរពគោលការណ៍អធិបតេយ្យជាតិ និង លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវគោរពទ្រព្យសម្បត្តិសាធារណៈ និងកម្មសិទ្ធិស្របច្បាប់របស់ឯកជន ។

# ជំពូកទី ៦
# អំពី អប់រំ វប្បធម៌ និងសង្គមកិច្ច

មាត្រា ៦៥--

រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ពលរដ្ឋក្នុងការទទួលការអប់រំប្រកប ដោយគុណភាពនៅគ្រប់កំរិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឱ្យ ការអប់រំនេះបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប ។

រដ្ឋយកចិត្តទុកដាក់ដល់វិស័យអប់រំកាយ និងកីឡាដែលជាសុខុមាលភាពរបស់ ប្រជាពលរដ្ឋខ្មែរគ្រប់រូប ។

មាត្រា ៦៦—

រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាពនៅទូទាំងប្រទេសដែលធានា ឱ្យបាន នូវគោលការណ៍សេរីភាពខាង សិក្សាធិការនិងគោលការណ៍សមភាពក្នុងការ អប់រំ ដើម្បីឱ្យប្រពលរដ្ឋគ្រប់រូបមានភ័ព្វ សំណាងគ្រប់គ្រាន់ ស្មើគ្នាក្នុងការកសាងជីវិត ។

មាត្រា ៦៧—

រដ្ឋអនុវត្តកម្មវិធីសិក្សា និងគោលការណ៍គរុកោសល្យ ទំនើប រាប់បញ្ចូលទាំងប ច្ចេកវិទ្យា និងភាសាបរទេស ។

រដ្ឋគ្រប់គ្រងគ្រឹះស្ថានសិក្សា និងថ្នាក់សិក្សាសាធារណៈ និងឯកជននៅគ្រប់ ភូមិ សិក្សា ។

មាត្រា ៦៨

រដ្ឋផ្តល់កិច្ចការអប់រំផ្នែកបឋម និងមធ្យមសិក្សានៅសាលារៀនសាធារណៈសំរាប់ ប្រជាពលរដ្ឋគ្រប់រូប ដោយឥតបង់ថ្លៃ ។

ប្រជាពលរដ្ឋ ត្រូវបានទទួលការអប់រំយ៉ាងតិចប្រាំបួនឆ្នាំ ។

រដ្ឋជួយផ្សព្វផ្សាយ និងលើកតំកើងសាលាបាលី និងពុទ្ធិកសិក្សា ។

## មាត្រា ៦៩—

រដ្ឋមានកាតព្វកិច្ចថែរក្សា និងពង្រីកវប្បធម៌ជាតិ ។រដ្ឋមានកាតព្វកិច្ចការពារ និងពង្រីកភាសាខ្មែរឱ្យសមស្របនឹងសេចក្តីត្រូវការ ។

រដ្ឋមានកាតព្វកិច្ចថែរក្សា និងការពារប្រាសាទបុរាណ វត្ថុសិល្បៈបុរាណ និងកែលំអរមណីយដ្ឋានប្រវត្តិសាស្ត្រឡើងវិញ ។

## មាត្រា ៧០—

បទល្មើសទាំងឡាយដែលប៉ះពាល់ ឬទាក់ទងនឹងបេតិកភ័ណ្ឌវប្បធម៌ និងបេតិកភ័ណ្ឌសិល្បៈ ត្រូវផ្តន្ទាទោសជាទម្ងន់ ។

## មាត្រា ៧១—

បរិវេណបេតិកភ័ណ្ឌជាតិ ក៏ដូចជាបេតិកភ័ណ្ឌដែលបានបញ្ចូលជាបេតិកភ័ណ្ឌពិភពលោក ត្រូវទុកជាតំបន់អព្យាក្រឹតដែលមិនឱ្យមានសកម្មភាពយោធា ។

## មាត្រា ៧២—

សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា ។ រដ្ឋយកចិត្តទុកដាក់ដល់ការការពារ ជម្ងឺ ។ ប្រជារាស្ត្រក្រីក្រត្រូវបានទទួលការពិនិត្យរោគដោយឥតបង់ថ្លៃ នៅតាមមន្ទីរ ពេទ្យ គិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈ។

រដ្ឋរៀបចំឱ្យមានគិលានដ្ឋាន និងមន្ទីរសម្ភពដល់ជនបទ ។

## មាត្រា ៧៣—

រដ្ឋយកចិត្តទុកដាក់ចំពោះកុមារនិងមាតា ។ រដ្ឋរៀបចំឱ្យមានទារកដ្ឋាន និងជួយឧបត្ថម្ភនាឬ្ទីដែលមានកូនច្រើន ក្នុងបន្ទុកហើយឥតទីពឹង ។

## មាត្រា ៧៤—

រដ្ឋជួយឧបត្ថម្ភជនពិការ និងដល់គ្រួសារយុទ្ធជន ដែលបានបូជាជីវិតដើម្បីប្រទេសជាតិ ។

## មាត្រា ៧៥—

រដ្ឋចាត់ចែងឱ្យមានរបបសន្តិសុខសង្គម ដល់កម្មករ និងនិយោជិក ។

# សៀវភៅយល់ដឹងពីសិទ្ធិមនុស្ស

រៀបរៀងដោយ

អង្គការសហការអន្តរជាតិកម្ពុជា(ICC) ខេត្តរតនគីរី

This Human Rights book
Illustrated by ICC Ratanakiri

បោះពុម្ពលើកទី១ ចំនួន៥០ច្បាប់

ឆ្នាំ ២០០៩

សូមរក្សាសិទ្ធិគ្រប់យ៉ាង

អង្គការសហការ
INTERNATIONAL
COOPERATION
CAMBODIA
RIDE PROJECT

Prepared for first online distribution in July 2014 by

អង្គការសហការអន្តរជាតិកម្ពុជា

International Cooperation Cambodia

P.O. Box 612

Phnom Penh, Cambodia

Tel: 092-469-934 / 075-974-029

http://www.icc.org.kh

ams.rtk.ibcde@icc.org.kh

This work is licensed under the Creative Commons Attribution-ShareAlike 4.0 International License. To view a copy of this license, visit http://creativecommons.org/licenses/by-sa/4.0/.

**You are free to:**

**Share** — copy and redistribute the material in any medium or format
**Adapt** — remix, transform, and build upon the material
for any purpose, even commercially.
The licensor cannot revoke these freedoms as long as you follow the license terms.

**Under the following terms:**

**Attribution** — You must give appropriate credit, provide a link to the license, and indicate if changes were made. You may do so in any reasonable manner, but not in any way that suggests the licensor endorses you or your use.

**ShareAlike** — If you remix, transform, or build upon the material, you must distribute your contributions under the same license as the original.
**No additional restrictions — You may not apply legal terms or technological measures that legally restrict others from doing anything the license permits.**